# ព្រះរាជក្រម

នស/រកម/១០០៤/០០៣

## យើង

## ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

## រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

## និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

## ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស /រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស ឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់លិខិតលេខ ២៥៦រស. ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០០៤ របស់រដ្ឋសភា ស្តីពីសំណើសុំធ្វើព្រះរាជក្រមប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃ ក្រុមប្រឹក្សារាជសម្បត្តិ

-បានទ្រង់យល់សេចក្តីសំរេចលេខ ០៦៤/០០៦/២០០៤ កបធ.ច ចុះថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០០៤ របស់ក្រុមប្រឹក្សាធម្មនុញ្ញ

-បានទ្រង់យល់សំណើរបស់នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីការការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សារាជសម្បត្តិ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ៨ ខែ តុលា ឆ្នាំ ២០០៤ នាសម័យប្រជុំពេញអង្គលើកទី ១ នីតិកាលទី ៣ ហើយដែលព្រឹទ្ធសភាបានអនុម័តយល់ស្របលើទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០០៤ នាសម័យប្រជុំពេញអង្គលើកទី ៩ នីតិកាលទី ១ ព្រមទាំងត្រូវបានក្រុមប្រឹក្សាធម្មនុញ្ញប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញតាមសេចក្តីសំរេចលេខ ០៦៤/០០៦/២០០៤ កបធ.ច ចុះថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០០៤ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ:

# ច្បាប់ស្តីពី
# ការរៀបចំ និង ការប្រព្រឹត្តទៅ
# នៃក្រុមប្រឹក្សារាជសម្បត្តិ

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះមានគោលដៅកំណត់ការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សារាជសម្បត្តិ ដើម្បីជ្រើសរើសព្រះមហាក្សត្រ និងធានានូវដំណើរការជាប្រក្រតីនៃរបបរាជានិយមអាស្រ័យដោយរដ្ឋធម្មនុញ្ញ ។

**មាត្រា ២ .-**

ការជ្រើសរើសព្រះមហាក្សត្រថ្មីជាសមត្ថកិច្ចរបស់ក្រុមប្រឹក្សារាជសម្បត្តិ ។

## ជំពូកទី ២
## ការរៀបចំ និង សមាសភាពនៃក្រុមប្រឹក្សារាជសម្បត្តិ

**មាត្រា ៣ .-**

អនុលោមតាមមាត្រា ១៣ ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា សមាសភាពក្រុមប្រឹក្សារាជសម្បត្តិ មានដូចខាងក្រោម :

| | |
|---|---|
| ១-ប្រធានព្រឹទ្ធសភា | ប្រធាន |
| ២-ប្រធានរដ្ឋសភា | អនុប្រធានទី ១ |
| ៣-នាយករដ្ឋមន្ត្រី | អនុប្រធានទី ២ |
| ៤-សម្តេចព្រះសង្ឃរាជគណៈមហានិកាយ | សមាជិក |
| ៥-សម្តេចព្រះសង្ឃរាជគណៈធម្មយុត្តិកនិកាយ | សមាជិក |
| ៦-អនុប្រធានទី ១ ព្រឹទ្ធសភា | សមាជិក |
| ៧-អនុប្រធានទី ១ រដ្ឋសភា | សមាជិក |
| ៨-អនុប្រធានទី ២ ព្រឹទ្ធសភា | សមាជិក |
| ៩-អនុប្រធានទី ២ រដ្ឋសភា | សមាជិក |

**មាត្រា ៤ .-**

ប្រធានក្រុមប្រឹក្សារាជសម្បត្តិដឹកនាំអង្គប្រជុំក្រុមប្រឹក្សារាជសម្បត្តិ ទទួលអាណត្តិ សេចក្តីសម្រេចនានា ដែលក្រុមប្រឹក្សារាជសម្បត្តិបានអនុម័ត ចាត់ចែងនិងរ៉ាប់រងការអនុវត្តនីច្បាប់ទាំងឡាយដែលទាក់ទងនឹងការគ្រងរាជសម្បត្តិរបស់ព្រះមហាក្សត្រ ។

**មាត្រា ៥ .-**

ក្នុងករណីដែលប្រធានក្រុមប្រឹក្សារាជសម្បត្តិអវត្តមាន ឬ ពុំមានលទ្ធភាពបំពេញមុខងារបានដោយមានមូលហេតុច្បាស់លាស់ អនុប្រធានក្រុមប្រឹក្សារាជសម្បត្តិត្រូវទទួលភារកិច្ចចាត់ចែងការជំនួស ។

**មាត្រា ៦ .-**

ក្នុងករណីដែលប្រធាននិងអនុប្រធានក្រុមប្រឹក្សារាជសម្បត្តិអវត្តមាន ឬពុំមានលទ្ធភាពបំពេញមុខងារ បានដោយមានមូលហេតុច្បាស់លាស់ ក្រុមប្រឹក្សារាជសម្បត្តិនឹងត្រូវដឹកនាំដោយ :

-អនុប្រធានទី ១ ព្រឹទ្ធសភា ប្រធាន

-អនុប្រធានទី ១ រដ្ឋសភា អនុប្រធាន

**មាត្រា ៧ .-**

រដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំងត្រូវទទួលបន្ទុករៀបចំទីកន្លែងប្រជុំ កន្លែងធ្វើការនិងធ្វើកំណត់ហេតុរបស់ក្រុមប្រឹក្សារាជសម្បត្តិ បន្ថែមលើភារកិច្ចបច្ចុប្បន្ន ។

កំណត់ហេតុនិងឯកសារទាំងអស់របស់ក្រុមប្រឹក្សារាជសម្បត្តិត្រូវរក្សាទុកក្នុងក្រសួងព្រះបរមរាជវាំង ហើយមិនត្រូវធ្វើឱ្យខូចខាតទៅក្រៅឡើយ ។

## ជំពូកទី ៣
## ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សារាជសម្បត្តិ

**មាត្រា ៨ ._**

កិច្ចប្រជុំរបស់ក្រុមប្រឹក្សារាជសម្បត្តិ ត្រូវកោះអញ្ជើញដោយប្រធានក្រុមប្រឹក្សារាជសម្បត្តិ ។ សមាជិកបីរូបយ៉ាងតិច អាចលើកសំណើសុំអោយកោះប្រជុំបាន ។

កិច្ចប្រជុំរបស់ក្រុមប្រឹក្សារាជសម្បត្តិចាត់ទុកជាបានការ លុះត្រាតែមានសមាជិកប្រាំរូបយ៉ាងតិចឡើងទៅចូលរួមប្រជុំ ។ ការពិភាក្សានៃកិច្ចប្រជុំរបស់ក្រុមប្រឹក្សារាជសម្បត្តិត្រូវទុកជាការសម្ងាត់ ។

**មាត្រា ៩._**

ការអនុម័តរបស់ក្រុមប្រឹក្សារាជសម្បត្តិ ត្រូវយកតាមមតិភាគច្រើនដាច់ខាតគឺប្រាំសម្លេងឡើង តាមរយៈការបោះឆ្នោតដោយសម្ងាត់ ។

**មាត្រា ១០._**

ក្នុងរយៈវេលា ៧ ថ្ងៃយ៉ាងយូរ ក្រោយពីពេលព្រះមហាក្សត្រទ្រង់ចូលទីវង្គត ឬ ចូលនិវត្តន៍ ឬដាក់រាជ្យ ក្រុមប្រឹក្សារាជសម្បត្តិ ត្រូវជ្រើសរើសព្រះមហាក្សត្រថ្មីនៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ១១ ._**

ត្រូវបានជ្រើសរើសជាព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា សមាជិកនៃព្រះរាជវង្សានុវង្សខ្មែរណាដែលមានព្រះជន្មាយុយ៉ាងតិច ៣០ ព្រះវស្សា ដែលជាព្រះរាជបច្ឆាញាតិនៃព្រះមហាក្សត្រ អង្គឌួង ឬព្រះមហាក្សត្រ នរោត្តម ឬក៏ព្រះមហាក្សត្រ ស៊ីសុវត្ថិ ហើយដែលក្រុមប្រឹក្សារាជសម្បត្តិយល់ឃើញថាមានកាយសម្បទា និងសមត្ថភាពគ្រប់គ្រាន់ក្នុងការបម្រើប្រជារាស្ត្រប្រជាជាតិនិងមាតុភូមិ ។

**មាត្រា ១២.-**

សមាជិកក្រុមប្រឹក្សារាជសម្បត្តិ ចាប់ពីបីរូបឡើងអាច ឧទ្ទេសនាមបេក្ខជនព្រះមហាក្សត្រថ្មីមួយអង្គបាន ។ សមាជិកក្រុមប្រឹក្សារាជសម្បត្តិមួយរូប មានសិទ្ធិឧទ្ទេសនាមបានតែបេក្ខជនមួយអង្គប៉ុណ្ណោះ ។

**មាត្រា ១៣.-**

សេចក្តីសម្រេចរបស់ក្រុមប្រឹក្សារាជសម្បត្តិស្តីពីការជ្រើសរើសព្រះមហាក្សត្រថ្មី ត្រូវផ្សព្វផ្សាយជាសាធារណៈ ដោយរដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង ។

**មាត្រា ១៤.-**

មុនចូលគ្រងរាជសម្បត្តិ ព្រះមហាក្សត្រថ្មី ទ្រង់ថ្លែងសច្ចាប្រណិធានដូចមានចែងក្នុងឧបសម្ព័ន្ធ ៤ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា នៅថ្ងៃបន្ទាប់ពីថ្ងៃដែលក្រុមប្រឹក្សារាជសម្បត្តិចេញសេចក្តីសម្រេច ដូចមានចែងក្នុងមាត្រា ១៣ នៃច្បាប់នេះ ។

**មាត្រា ១៥.-**

ព្រះរាជពិធីអភិសេកព្រះមហាក្សត្រថ្មីតាមប្រពៃណីទំនៀមទម្លាប់នៃព្រះរាជវង្សានុវង្សខ្មែរអាចប្រព្រឹត្តទៅមុនពេលទ្រង់ថ្លែងសច្ចាប្រណិធាន ដូចមានចែងក្នុងមាត្រា ១៤ នៃច្បាប់នេះ ។

ក្នុងករណីកាលៈទេសៈមិនអនុគ្រោះ ព្រះរាជពិធីអភិសេកនេះអាចនឹងលើកទៅធ្វើនៅក្រោយពេលប្រារព្ធព្រះរាជពិធីបុណ្យឈាបនកិច្ចថ្វាយព្រះសពព្រះមហាក្សត្របាន ។

## ជំពូកទី ៤

## បទប្បញ្ញត្តិពិសេស

**មាត្រា ១៦.–**

ព្រះមហាក្សត្រដែលទ្រង់បានយាងចូលនិវត្តន៍ ឬដាក់រាជ្យ និងព្រះមហេសី ត្រូវបានរក្សាបុព្វសិទ្ធិ អភ័យឯកសិទ្ធិពេញលេញ និងមិនអាចនរណារំលោភបំពានបានឡើយ ដូចពេលដែលព្រះអង្គនៅគ្រងរាជសម្បត្តិ ។

## ជំពូកទី ៥

## អវសានបញ្ញត្តិ

**មាត្រា ១៧.–**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ១៨.–**

ច្បាប់នេះ ត្រូវបានប្រកាសជាការប្រញាប់ ។

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០០៤

ក្នុងព្រះបរមនាម និងតាមព្រះរាជបន្ទូលបង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា និងព្រះរាជលញ្ឆករ

ជា ស៊ីម

ពរស.០៤១០.៣០៧

បានយកសេចក្តីជម្រាបជូនសម្តេចប្រមុខរដ្ឋស្តីទី

" ដើម្បីសុំហត្ថលេខា "

នាយករដ្ឋមន្ត្រី

ហត្ថលេខា

ហ៊ុន សែន

លេខ ៧៣៩ ចល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី២១ ខែ តុលា ឆ្នាំ២០០៤

អគ្គលេខាធិការរាជរដ្ឋាភិបាល

ឈាង តាន់